## ធម្មទេសនារបស់លោកអភិបាលអូលីវីយេ
## ខួប២៥ឆ្នាំនៃវត្តមានក្រុមបងស្រីសាឡេស៊ាននៅកម្ពុជា
## ថ្ងៃទី០៩ វិច្ឆិកា ២០១៧

អត្ថបទទី១៖អគ ៤៧,១-២.៨-៩.១២
ដំណឹងល្អ៖យហ ២,១៣-២២

បងប្អូនជាទីស្រឡាញ់!

**ខ្ញុំសូមលើកតម្កើង អំពើដ៏សប្បុរសរបស់ព្រះអម្ចាស់ ខ្ញុំសរសើរតម្កើងព្រះអម្ចាស់ចំពោះកិច្ចការទាំងប៉ុន្មានដែលព្រះអង្គបានប្រព្រឹត្តិមកលើយើង។** ថ្ងៃនេះឱកាសដើម្បីលើកតម្កើងព្រះជាម្ចាស់ សម្រាប់វត្តមានបងស្រីនៅក្នុងប្រទេសកម្ពុជាអស់រយៈពេល២៥ឆ្នាំ។ នឹកឃើញដល់ប្រវត្តិសាស្រ្ត ២៥ឆ្នាំ ជាពិសេសក្មេងៗនៅទីនេះ ២៥ឆ្នាំមុនមិនទាន់កើត យើងនឹកឃើញបងស្រីមកដល់ ដើម្បីចាប់ផ្ដើមសាលាដុនបូស្កូ ដែលបានចាប់ផ្ដើមពីដើមនៅកន្លែងដាច់ ប៉ុន្តែសព្វថ្ងៃយើងឃើញអ្វីដែលបងស្រីបានចាប់ផ្ដើមកើតឡើង ណែនាំឲ្យយើងមានអំណរសប្បាយ។ ថ្ងៃនេះយើងអរព្រះគុណព្រះជាម្ចាស់ រួមជាមួយព្យាការីអេសាយ លើកតម្កើងព្រះជាម្ចាស់ សម្រាប់២៥ឆ្នាំដែលបងស្រីបានយកចិត្តទុកដាក់បំពេញបេសកកម្មដែលបានទទួលពីលោកឪពុកបូស្កូ ដែលទទួលពីបងស្រីម៉ាសេរេឡូ ដើម្បីអប់រំណែនាំយុវជនយុវនារីឲ្យរៀបចំខ្លួន ទៅជាពលរដ្ឋដែលមានចិត្តស្មោះ ដើម្បីគោរពស្រឡាញ់ថ្លៃថ្នូរ ដើម្បីរស់នៅក្នុងសេចក្ដីសុខសាន្ត និងដើម្បីជួយកសាងប្រទេសផ្ទាល់ខ្លួន។ ពីសាលាមត្តេយ្យសិក្សារហូតដល់សាលាឯកទេស នេះទាំងអស់ជាកម្មវិធីសិក្សាដែលណែនាំឲ្យយើងអរគុណព្រះជាម្ចាស់ សម្រាប់អ្វីៗទាំងអស់ដែលបងស្រីបានប្រគល់ដល់សង្គមខ្មែរ។

ទំនុកតម្កើង **ទោះបីព្រះអម្ចាស់ ខ្ពង់ខ្ពស់ខ្លាំងណាស់ ក៏ទ្រង់សំភឺ គិតមនុស្សលោកគ្រប់នាទី** ទោះបីព្រះជាម្ចាស់ខ្ពង់ខ្ពស់ដល់កំពូល ព្រះជាម្ចាស់យកចិត្តទុកដាក់គ្រប់នាទីដើម្បីស្គាល់ ដើម្បីមើល ដើម្បីបង្កើតទំនាក់ទំនងជាមួយមនុស្សលោក។ នេះជាបេសកកម្មទីមួយ ដែលបងស្រីបានបំពេញ ធ្វើយ៉ាងម៉េចដើម្បីទុកអទិភាពឲ្យមនុស្សម្នាក់រីកចម្រើន។ ប៉ុន្មានឆ្នាំមុន ខ្ញុំថាបងស្រីសុំជួយបើកសាលាវិទ្យាល័យ ដោយសារពេលនោះបងស្រីមានតែមត្តេយ្យនិងបឋមសិក្សា បងស្រីថា យើងមានបងស្រីតិចពេក យើងបើកសាលាមិនបានទេ។ ខ្ញុំប្រាប់បងស្រីថា បើសាលាមួយមានបងស្រីម្នាក់ល្មមហើយ។ ដូច្នេះខ្ញុំយល់ថា យើងធ្វើយ៉ាងម៉េចដើម្បីឲ្យមនុស្សម្នាក់មានតម្លៃដ៏ខ្ពង់ខ្ពស់ ដូច្នេះ យើងមានសិស្សានុសិស្សច្រើន ត្រូវការមានបងស្រីច្រើន ដើម្បីស្គាល់គ្នា ដើម្បីណែនាំគ្នា ដើម្បីលើកទឹកចិត្តគេ ដើម្បីធ្វើដំណើរជាមួយគេ មិនមែនតែអប់រំទូទៅ មិនមែនតែណែនាំទូទៅ ប៉ុន្តែស្គាល់ម្នាក់ៗ។

មានឪពុកម្ដាយច្រើន ចង់ឲ្យកូនចូលរៀននៅទីនេះដោយសារមានការសិក្សាល្អ ដោយសារបងស្រីយកចិត្តទុកដាក់ជាមួយមនុស្សម្នាក់ ដើម្បីធ្វើដំណើរជាមួយគាត់ ឲ្យគាត់រីកចម្រើនពីមត្តេយ្យសិក្សាដល់វិទ្យាល័យ ឲ្យគាត់យល់ដឹងអំពីខ្លួនឯង យល់ដឹងអំពីជីវិតផ្ទាល់ ដើម្បីកសាងអនាគត និងដើម្បីរស់នៅក្នុងសេចក្ដីសុខសាន្ត នៅក្នុងជីវិតផ្ទាល់ពេលបង្កើតគ្រួសារ។ ខ្ញុំយល់ថា នេះជាអ្វីដែលណែនាំឲ្យយើងយល់ពិតមែន ជីវិតមានតម្លៃណាស់។ ការសិក្សានៅសាលាដុនបូស្កូ តាមគរិកោសល្យរបស់លោកឪពុកបូស្កូ មិនមែនតែការបង្រៀនចំណេះដឹង តែបង្រៀនចិត្តគំនិត បង្រៀនរូបកាយ និងអ្វីៗទាំងអស់ដែលណែនាំឲ្យយើងជាមនុស្សពេញលក្ខណៈ។

នេះជាសញ្ញាសំគាល់មួយយ៉ាងពិសេសសម្រាប់សាលាទាំងអស់ និងសម្រាប់ក្រសួងអប់រំដែរ ដើម្បីយល់ថាយើងបង្រៀនចំណេះដឹងទូទៅ ប៉ុន្តែយើងមានបង្រៀនចិត្តគំនិតផង ដើម្បីទៅជាមនុស្សពេញលក្ខណៈ ដែលរស់នៅដោយមានចិត្តស្មោះនៅក្នុងយុត្តិធម៌នៅក្នុងសង្គម។ លិខិតរបស់សន្តប៉ូលថា ″**ព្រះអង្គនឹងធ្វើឲ្យបងប្អូនបានរឹងប៉ឹងភ្ជាប់ខ្លួន រហូតដល់ទីបំផុតអត់មានទោសពៃអ្វីនៅថ្ងៃដែលព្រះយេស៊ូគ្រីស្តជាព្រះអម្ចាស់នៃយើងយាងមក ជាពិសេសព្រះអង្គធ្វើឲ្យបងប្អូនបានរឹងប៉ឹងភ្ជាប់ខ្លួន**″ នេះជាតួនាទីរបស់បងស្រី។ បងស្រី ធ្វើដូចម្ដេចដើម្បីឲ្យចិត្តគំនិត ឲ្យខ្លួនរបស់យើងរឹងប៉ឹង ដើម្បីឲ្យខ្លួនយើងក្លាយជាយុវជនយុវនារីដែលចេះតស៊ូនៅក្នុងសង្គម និងទៅអនាគត់។ ការសិក្សាដែលយើងទទួលនៅទីនេះ មិនមែនជាការសិក្សាមួយងាយស្រួលទេ បងស្រីមានវិន័យ បងស្រីមានច្បាប់ បងស្រីមានរបៀប បងស្រីមានម៉ោងច្បាស់លាស់ បងស្រីណែនាំឲ្យយើងស្ដាប់ឲ្យយើងគោរព ជាមូលហេតុត្រូវការបងស្រីច្រើន ដើម្បីឲ្យសាលារបស់យើងមានការីកចម្រើនថែមទៀត។

យើងយល់ថា ពិតមែនការសិក្សាដែលយើងទទួលជាការសិក្សាដែលជោគជ័យ លុះត្រាតែយើងយកចិត្តទុកដាក់នៅក្នុងការតស៊ូ។ សិស្សានុសិស្សទាំងអស់កុំភ្លេចនេះ ដោយសារនៅក្នុងសង្គមទំនើបៗ ការតស៊ូអត់សូវមានប៉ុន្មានទេ។ បើសិស្សានុសិស្សនឹកឃើញដល់តាយាយ បានតស៊ូច្រើនណាស់ ឪពុកម្ដាយផ្ទាល់ខ្លួនបានតស៊ូច្រើនណាស់ ប៉ុន្តែឥលូវនេះយើងចង់មានជីវិតស្រួលជូនកាលយើងគិតថាយើងចូលរៀនសាលាដុនបូស្កូស្រួលណាស់ មានភ្លើង មានទឹក មានកង្ហា មានម្ហូប មានគ្រូបង្រៀនដ៏ល្អ មានកន្លែងហាត់កីឡាស្អាត មានសួនច្បារ។ នៅពេលយើងទៅផ្ទះអត់មានទឹក អត់មានភ្លើង អត់មានកន្លែងដេកត្រឹមត្រូវ នេះកុំអោយភ្លេចតស៊ូ។ តស៊ូដើម្បីរីកចម្រើនដោយសារសញ្ញាបត្រដែលយើងទទួលទៅថ្ងៃអនាគត ប្រសិនបើយើងមិនចេញកំលាំងផ្ទាល់ខ្លួនប្រសិនបើយើងមិនចេញការតស៊ូនៅក្នុងជីវិត យើងមិនអាចប្រើសញ្ញាបត្ររបស់យើងដើម្បីទៅមុខទៀត។ ដូច្នេះ ការតស៊ូណែនាំឲ្យយើងជោគជ័យនៅក្នុងជីវិតរបស់យើង នេះជាអ្វីដែលបងស្រីណែ

នាំដើម្បីឲ្យចិត្តគំនិតរបស់យើង ឲ្យខ្លួនរបស់យើងរឹងប៉ឹងជានិច្ច នៅក្នុងការតស៊ូដើម្បីជោគជ័យនៅក្នុងជីវិតនាពេលអនាគត។

អត្ថបទគម្ពីដែលបងស្រីរើសថ្ងៃនេះ ជាព្រះយេស៊ូលើកទីមួយដែលព្រះយេស៊ូបង្ហាញសញ្ញាសម្គាល់ លើកទីមួយដែលព្រះយេស៊ូចេញពីភូមិណាសារ៉ែត រួមជាម្តាយ រួមជាមួយបងប្អូន នៅពេលនោះព្រះយេស៊ូ ទៅចូលរួមអាពាហ៍ពិពាហ៍គេ។ យើងគិតថា ព្រះយេស៊ូប្រហែលមកដើម្បីនិយាយអំពីព្រះរាជ្យរបស់ព្រះជាម្ចាស់ អំពីធម៌វិន័យរបស់ព្រះជាម្ចាស់ មុនគេបង្អស់ព្រះអង្គចូលរួមមង្គលការ ប៉ុន្តែមិនមែនមង្គលការធម្មតាទេ ព្រះយេស៊ូចូលក្នុងមង្គលការនឹងគាត់ធ្វើឲ្យមង្គលការនេះសប្បាយខ្លាំងៗទៅ ដោយសារព្រះយេស៊ូបានកែប្រែទឹកឲ្យក្លាយទៅជាស្រាទំពាំងបាយជូរ យ៉ាងឆ្ងាញ់បំផុត។ បងស្រីមានកម្មវិធីការសិក្សាដោយជោគជ័យ ដោយសារបងស្រីពោរពេញដោយអំណរសប្បាយដែលមកពីព្រះជាម្ចាស់ និងបងស្រីចែករំលែកអំណរសប្បាយនេះ។ សម្តេចប៉ាបធ្លាប់និយាយថា **កន្លែងណាមានបងស្រី កន្លែងហ្នឹងមានអំណរសប្បាយ**។ បងស្រីថា បេសកកម្មរបស់យើងគឺធ្វើដូចម្តេច ដើម្បីផ្តល់សក្ខីភាពអំពីជីវិតរបស់ព្រះជាម្ចាស់ ជីវិតយ៉ាងបរិបូរណ៍ និងសក្ខីភាពនេះមិនមែនចេញដោយសារបងស្រីប្រកាសដំណឹងល្អ មិនមែនដោយសារបងស្រីណែនាំឲ្យសិស្សានុសិស្សទាំងអស់ចូលអភិបូជាទោះបីមិនមែនគ្រីស្តបរិស័ទ។ ជីវិតផ្ទាល់របស់បងស្រី ពីមួយថ្ងៃទៅមួយថ្ងៃនៅក្នុងការយកចិត្តទុកដាក់បង្ហាញអំណរសប្បាយ បង្ហាញសេចក្តីសុខ ចែករំលែកអំណាសប្បាយមកពីព្រះជាម្ចាស់ មិនមែនអំណាសប្បាយមកពីលោកិយទេ ប្រសិនបើអំណរសប្បាយនេះមកពីលោកិយ បងស្រីតស៊ូអត់បានទេ បងស្រីមកទីនេះ២៥ឆ្នាំ បានតស៊ូទាំងផ្លូវយ៉ាប់ ទាំងអត់មានភ្លើង ទាំងរកលុយសាងសងអាគារ បងស្រីតស៊ូច្រើនណាស់ ប៉ុន្តែបងស្រីតស៊ូនៅក្នុងអំណរសប្បាយ ដោយសារអំណរសប្បាយនេះមកពីព្រះជាម្ចាស់។ ផ្លែ គឺសិស្សានុសិស្សមានអនាគត់ ជាពិសេសយើងមានបងស្រីខ្មែរយើងបីនាក់។

ដូច្នេះយើងដឹងថានេះសញ្ញាសម្គាល់នៃអំណរសប្បាយ និងអំណរសប្បាយនេះចូលនៅក្នុងដួងចិត្តយុវនារីមួយចំនួន ដើម្បីបន្តបេសកកម្មរបស់បងស្រី។ យើងសប្បាយចិត្ត ដែលយើងទទួលក្មេងៗដើម្បីបន្តបេសកកម្ម។ ដូច្នេះបងស្រីខ្មែរទាំងបីនាក់ មានតួនាទីមួយពិសេសណាស់ ធ្វើដូចម្តេចឲ្យជីវិតរបស់យ៉ូហានដុនបូស្កូ និងបងស្រីម៉ាសារេឡូចូលយ៉ាងជ្រៅទៅក្នុងវប្បធម៌របស់យើង ចូលយ៉ាងជ្រៅនៅក្នុងរបៀបរស់នៅទីនេះ ដើម្បីកែប្រែរបៀបរស់នៅទីនេះផង និងឲ្យយើងកែប្រែចូលនៅក្នុងសង្គមរបស់យើងដែរ។ ព្រះបន្ទូលរបស់ព្រះជាម្ចាស់ បំភ្លឺជីវិតនៃសង្គមបច្ចុប្បន្ននេះ និងសង្គមរបស់យើងបំភ្លឺជីវិតរបស់យើងដែរ តាមរយៈព្រះបន្ទូលរបស់ព្រះជាម្ចាស់។ នេះជាចំនុចសំខាន់មួយ ដែលខ្ញុំសង្ឃឹមថាបងស្រីនិងក្មេងៗនឹងជួយអនុវត្តន៍ដើម្បីឲ្យយើងទៅមុខ ទៅមុខក្នុង

អំណរសប្បាយ និងនៅក្នុងការបម្រើដោយសារជីវិតរបស់បងស្រី គឺសេចក្តីស្រឡាញ់ អំណរសប្បាយ និងបម្រើ។

ព្រះនាងម៉ារី បាននិយាយតែមួយម៉ាត់ថា **ពេលលោកប្រាប់ឲ្យធ្វើអ្វីសូមធ្វើតាមលោកទៅ** នេះជារបៀបព្រះនាងម៉ារី នេះជារបៀបបងស្រី។ យើងជាអ្នកបម្រើ យើងធ្វើតាមអ្វីដែលព្រះយេស៊ូមានព្រះបន្ទូលដើម្បីអនុវត្តន៍ ដើម្បីរស់នៅក្នុងព្រះហឫទ័យរបស់ព្រះជាម្ចាស់ជានិច្ច។ ខ្ញុំសង្ឃឹមថានៅថ្ងៃណាមួយយើងមានបងស្រីទៅជួយខ្លះៗ ដើម្បីមានបេសកកម្មជាមួយសាលាកាតូលិកខេត្តតាកែវ។ ដូច្នេះយើងសង្ឃឹម យើងអាចសហាការជាមួយបងស្រីថែមទៀត ដើម្បីអប់រំយុវជនយុវនារី ដើម្បីឲ្យយុវជនយុវនារីនៅប្រទេសកម្ពុជាយ៉ាងច្រើនថែមទៀតតាមរយៈបងស្រី តាមរយៈលោកឪពុកបូស្តទទួលជីវិតដ៏បរិបូរណ៍។

យើងអរព្រះគុណព្រះជាម្ចាស់ សុំព្រះវិញ្ញាណដ៏វិសុទ្ធគង់នៅថែមទៀត ដើម្បីឲ្យ២៥ឆ្នាំខាងមុខទៀត ទៅជា២៥ឆ្នាំដែលយើងសាបព្រោះថែមទៀត។ ខ្ញុំសង្ឃឹមថា ២៥ឆ្នាំខាងមុខសិស្សានុសិស្សនៅទីនេះ នឹងក្លាយជាឪពុកម្តាយដ៏ល្អ ដែលណែនាំកូនចៅឲ្យក្លាយជាពលរដ្ឋដ៏ល្អនៅក្នុងសង្គម។ សូមព្រះអង្គប្រទានពរ ឲ្យបងស្រីមានកម្លាំងកាយចិត្ត សេចក្តីស្រឡាញ់ ជំនឿថែមទៀត ដើម្បីបម្រើអស់ពីដួងចិត្តអស់ពីស្មារតី និងអស់ពីសេចក្តីស្រឡាញ់។ អាម៉ែន៕